ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២១ លេខ៧៩ ត្រីមាសទី០៤ ឆ្នាំ២០២១

# រាជកិច្ច

ផ្សាយចេញពី

ទីស្ដីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច បទបញ្ជា សារាចរ ប្រកាស

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២២-១២-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨៦២ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **យ៉ាង ឆោវ** (YANG CHAO) ជនជាតិចិន សញ្ជាតិចិន ដោយប្តូរឈ្មោះជា **ចូវ អាឡែន** (ZHOU ALLEN) ៩៧៤៥

២២-១២-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨៦៣ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ចឹង វៃសឹង** (ZENG WEISHENG) ជនជាតិចិន សញ្ជាតិចិន ដោយប្តូរឈ្មោះជា **គូ សុង** (GU SONG) ៩៧៤៦


## II~រាជរដ្ឋាភិបាល

### អនុក្រឹត្យ


២៤-១២-២០២១ -អនុក្រឹត្យលេខ ២៥៩ អនក្រ.បក ស្តីពី ការកាត់ផ្ទៃដីទំហំ ៩៩ ហិកតា ៧១ អា ០៨ សង់ទីអា ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគផ្ទៃដីទំហំ ៦៥ ហិកតា ៧៤ អា ជាដីឯកជនរបស់រដ្ឋ ដើម្បីប្រទានកម្ម ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផលជាក់ស្តែង ចំនួន ១៩៦ គ្រួសារ និងរក្សាទុកផ្ទៃដីទំហំ ៣៣ ហិកតា ៩៧ អា ០៨ សង់ទីអា ជាដីសាធារណៈ របស់រដ្ឋ ព្រមទាំងផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី ស្ថិតនៅភូមិបាចុង សង្កាត់ព្រះបាទ ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ៩៧៤៧

២៨-១២-២០២១ -អនុក្រឹត្យលេខ ២៦០ អនក្រ.បក ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការប្រឆាំងដូប៉ានៃកម្ពុជា ៩៧៤៩

៣០-១២-២០២១ -អនុក្រឹត្យលេខ ៥៩៥ អនក្រ.តត ស្តីពី ការសម្រួលភារកិច្ចមន្ត្រីរាជការ ៩៧៥៥


## III~ការងារបណ្តាក្រសួង

### ១~ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


៣-១១-២០២១ -ប្រកាសលេខ ៧៣៦ សហវ.ប្រក ស្តីពី ការតែងតាំងភ្នាក់ងារបើកផ្តល់ និងភ្នាក់ងារបើកផ្តល់ជំនួសនៅអគ្គាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៩៧៥៦

៣-១១-២០២១ -ប្រកាសលេខ ៧៣៧ សហវ.ប្រក ស្តីពី ការតែងតាំងរដ្ឋទេយ្យករបុរេប្រទាន និងរដ្ឋទេយ្យករបុរេប្រទានរង នៅអគ្គាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៩៧៥៩


### ២~ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍


២២-៦-២០២១ -ប្រកាសលេខ ២០៩ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស្មៀល ហាប់ លីមីធីត បង្កើតរោងចក្រ ផលិតបំពង់ទីបដែកឧស្សាហកម្ម ៩៧៦២

២២-៦-២០២១ -ប្រកាសលេខ ២១០ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ូមីត្រូនិច មេនញូហ្វេកធើរីង (ខេមបូឌា) បង្កើតរោងចក្រ ផលិតគ្រឿងបង្គុំអេឡិចត្រូនិក ៩៧៦៥

២៥-៦-២០២១ -ប្រកាសលេខ ២១៣ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន សានយ័ន (អូវើស៊ី) បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៩៧៦៨

២៥-៦-២០២១ -ប្រកាសលេខ ២១៤ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ញូនៀន អ៊ិនសេនស៍ (ខេមបូឌា) អិនដាសស្ទ្រី ឯ.ក បង្កើតរោងចក្រ ផលិតធូបមូស ៩៧៧១

២៥-៦-២០២១ -ប្រកាសលេខ ២១៥ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន យូនីកតា ថេកណូឡូជី (ខេមបូឌា) បង្កើតរោងចក្រ ផលិត និងផ្គុំខ្សែភ្ជាប់គ្រឿងបរិក្ខារអេឡិកត្រូនិក ៩៧៧៤

២៥-៦-២០២១ -ប្រកាសលេខ ២១៦ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្វ៊ូស៊ីន ស្ទីល ប៊ីលឌីង បង្កើតរោងចក្រ ផលិតសម្ភារៈសំណង់ផ្សេងៗធ្វើពីដែក និងដែកប្រភេទH ៩៧៧៧

២៨-៦-២០២១ -ប្រកាសលេខ ២១៨ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជីនជិន (ខេមបូឌា) អ៊ិនធីឌី បង្កើតរោងចក្រ ផលិតប្រដាប់ព្យួរសម្លៀកបំពាក់ ៩៧៨០

២៨-៦-២០២១ -ប្រកាសលេខ ២១៩ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជីហ្វា ហ៉រហឺ (ខេមបូឌា) នីតធីង ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ និងបោកគក់ ៩៧៨៣

២០-៩-២០២១ -ប្រកាសលេខ ៣៣៤ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ខូលីធី តេក្សស្ទីល ខូអែលធីឌី បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៩៧៨៦

២០-៩-២០២១ -ប្រកាសលេខ ៣៣៥ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ឃែនធើរេន អ៊ីភែរឺល (ខេមបូឌា) បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៩៧៨៩

២០-៩-២០២១ -ប្រកាសលេខ ៣៣៧ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន បេសធែក តែកឃីជីង (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ ផលិតសម្ភារៈវេចខ្ចប់ ៩៧៩២

## ៣~ទីស្តីការរដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល

២៥-១១-២០២០ -ប្រកាសលេខ ០៥៩១ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៥៩១ រថ.អប្រក.លអ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៩៧៩៥

២៥-១១-២០២០ -ប្រកាសលេខ ០៥៩២ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៥៩២ រថ.អប្រក.លអ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៩៧៩៩

២៥-១១-២០២០ -ប្រកាសលេខ ០៥៩៥ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៥៩៥ រថ.អប្រក.លអ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៩៨០៣

២៥-១១-២០២០ -ប្រកាសលេខ ០៥៩៦ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៥៩៦ រថ.អប្រក.លអ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៩៨០៧

២៥-១១-២០២០ -ប្រកាសលេខ ០៥៩៧ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៥៩៧ រថ.អប្រក.លអ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៩៨១១

២៥-១១-២០២០ -ប្រកាសលេខ ០៥៩៨ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០៥៩៨ រថ.អប្រក.លអ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៩៨១៥

២៥-១១-២០២០ -ប្រកាសលេខ ០៥៩៩ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០៥៩៩ រថ.អប្រក.លអ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៩៨១៩

២៥-១១-២០២០ -ប្រកាសលេខ ០៦០១ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការមណ្ឌល
សន្និធិឧស្ម័ន អិល ភី ជី លេខ ០៦០១ រថ.អប្រក.លអ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៩៨២៣

២៦-១១-២០២០ -ប្រកាសលេខ ០៦០២ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០៦០២ រថ.អប្រក.លអ ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៩៨២៧

២៦-១១-២០២០ -ប្រកាសលេខ ០៦០៣ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០៦០៣ រថ.អប្រក.លអ ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៩៨៣១

២៦-១១-២០២០ -ប្រកាសលេខ ០៦០៤ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០៦០៤ រថ.អប្រក.លអ ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៩៨៣៥

២៦-១១-២០២០ -ប្រកាសលេខ ០៦០៥ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០៦០៥ រថ.អប្រក.លអ ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៩៨៣៩

២៦-១១-២០២០ -ប្រកាសលេខ ០៦០៦ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០៦០៦ រថ.អប្រក.លអ ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៩៨៤៣

២៦-១១-២០២០ -ប្រកាសលេខ ០៦០៧ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០៦០៧ រថ.អប្រក.លអ ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៩៨៤៧

២៦-១១-២០២០ -ប្រកាសលេខ ០៦០៨ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០៦០៨ រថ.អប្រក.លអ ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៩៨៥១

២៦-១១-២០២០ -ប្រកាសលេខ ០៦០៩ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០៦០៩ រថ.អប្រក.លអ ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៩៨៥៥

២៦-១១-២០២០ -ប្រកាសលេខ ០៦១០ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០៦១០ រថ.អប្រក.លអ ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៩៨៥៩

២៦-១១-២០២០ -ប្រកាសលេខ ០៦១១ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០៦១១ រថ.អប្រក.លអ ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៩៨៦៣


## ៤~ទីស្តីការរដ្ឋមន្ត្រីក្រសួងយុត្តិធម៌


១៦-៣-២០២១ -ប្រកាសលេខ ០៦១ កយ.ប្រក/២១ ស្តីពី ការដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរគ្មាន
បៀវត្ស ៩៨៦៧

# ព្រះរាជក្រឹត្យ

នស/រកត/១២២១/៥៦៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **យ៉ាង ឆាវ** (YANG CHAO) ជនជាតិ ចិន សញ្ជាតិ **ចិន** កើតនៅថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៨៤ នៅខេត្តហ៊ូប៉ី សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **ចូវ អាឡែន** (ZHOU ALLEN)។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ករ.២០១២.៥៥៣

នសីហមុនី

**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០២១

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/១២២១/៩៦៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ចឹង វៃស៊ឹង** (ZENG WEISHENG) ជនជាតិ ចិន សញ្ជាតិ ចិន កើតនៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៨១ នៅខេត្តក្វាងទុង សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **គូ សុង** (GU SONG)។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពរស.១២២១.៩៩៤

នរោត្តម សីហមុនី

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០២១*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ២៥៨ អនក្រ.បក

**អនុក្រឹត្យ**
**ស្តីពី**
**ការកាត់ផ្ទៃដីទំហំ ៩៩ ហិកតា ៧១ អា ០៨ សង់ទីអា ចេញពីដីតំបន់ព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគផ្ទៃដីទំហំ ៦៥ ហិកតា ៧៤ អា ជាដីឯកជនរបស់រដ្ឋ ដើម្បីប្រទានកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផលជាក់ស្តែង ចំនួន ១៩៦ គ្រួសារ និងរក្សាទុកផ្ទៃដីទំហំ ៣៣ ហិកតា ៩៧ អា ០៨ សង់ទីអា ជាដីសាធារណៈរបស់រដ្ឋ ព្រមទាំងផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី ស្ថិតនៅភូមិបាចុង សង្កាត់ព្រះបាទ ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា១ .-**

កាត់ផ្ទៃដីទំហំ ៩៩ ហិកតា ៧១ អា ០៨ សង់ទីអា ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគផ្ទៃដីទំហំ ៦៥ ហិកតា ៧៤ អា ជាដីឯកជនរបស់រដ្ឋ ដើម្បីប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ប្រើប្រាស់ និងអាស្រ័យផលជាក់ស្តែង និងរក្សាទុកផ្ទៃដីទំហំ ៣៣ ហិកតា ៩៧ អា ០៨ សង់ទីអា ជាដីសាធារណៈរបស់រដ្ឋ ស្ថិតនៅភូមិបាចុង សង្កាត់ព្រះបាទ ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ។

**មាត្រា២ .-**

ប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តស្ទឹងត្រែង ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ១៩៦ គ្រួសារ ស្ថិតនៅភូមិបាចុង សង្កាត់ព្រះបាទ ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។

**មាត្រា៣ .-**

ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនចំនួន ២០៨ ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ១៩៦ គ្រួសារ ស្ថិតនៅភូមិបាចុង សង្កាត់ព្រះបាទ ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។

**មាត្រា៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៥ រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ២៦០ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំនិងការប្រព្រឹត្តទៅ
# របស់គណៈកម្មាធិការប្រឆាំងដូប៉ាំនៃកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៤ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការប្រើប្រាស់សារជាតុដូប៉ាក្នុងវិស័យកីឡា
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ៤៦ អនក្រ.បក ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់នាយកដ្ឋានរៀបចំនិងគ្រប់គ្រងព្រឹត្តិការណ៍កីឡា និងមជ្ឈមណ្ឌលជាតិព័ត៌មានវិទ្យានិងស្ថិតិកីឡាចំណុះអគ្គនាយកដ្ឋានកីឡានៃក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតគណៈកម្មាធិការប្រឆាំងដូប៉ានៃកម្ពុជា ដែលសរសេរជាអក្សរកាត់ថា **គ.ប.ដ.ក.** និងជាភាសាអង់គ្លេស Cambodia Anti-Doping Committee ដែលសរសេរជាអក្សរកាត់ថា CADC ដើម្បីអនុវត្តអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា លិខិតបទដ្ឋានគតិយុត្ត និងវិធាននានាពាក់ព័ន្ធនឹងការប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា។

## ជំពូកទី២

## សមាសភាព តួនាទី និងភារកិច្ចរបស់ គ.ប.ដ.ក.

**មាត្រា២ .-**

**គ.ប.ដ.ក.** មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | ប្រធាន |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងការពារជាតិ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងយុត្តិធម៌១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងសុខាភិបាល១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា១រូប | អនុប្រធានប្រចាំការ |
| - រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងបរិស្ថាន១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងកិច្ចការនារី១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា២រូប | សមាជិក |
| - តំណាងគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា១រូប | សមាជិក |
| - តំណាងគណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា១រូប | សមាជិក |
| - តំណាងគណៈកម្មាធិការជាតិស្បែស្យាល់អូឡាំពិកកម្ពុជា១រូប | សមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា | សមាជិក |
| - អគ្គនាយករងនៃអគ្គនាយកដ្ឋានកីឡា១រូប | សមាជិក។ |

សមាសភាពជាក់ស្តែងរបស់ **គ.ប.ដ.ក.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៣ .-**

**គ.ប.ដ.ក.** មានតួនាទីជាសេនាធិការរបស់រាជរដ្ឋាភិបាលលើការអនុវត្តអនុសញ្ញាអន្តរជាតិស្តីពីការប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡានិងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំតាក់តែងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព បទប្បញ្ញត្តិផ្សេងៗពាក់ព័ន្ធនឹងការប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា
- រៀបចំកម្មវិធីអប់រំ បណ្តុះបណ្តាលប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា
- ផ្សព្វផ្សាយបទប្បញ្ញត្តិផ្សេងៗនិងអភិវឌ្ឍវិធានការប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា
- សិក្សាស្រាវជ្រាវនិងចងក្រងឯកសារអប់រំប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា
- សិក្សាស្រាវជ្រាវសារធាតុនិងវិធីហាមឃាត់ថ្មីៗ
- ប្រមូលសំណាកនិងត្រួតពិនិត្យសារធាតុដូប៉ាក្នុងចំណោមអត្តពលិក
- ផ្សព្វផ្សាយបញ្ជីសារធាតុនិងវិធីសាស្ត្រហាមឃាត់ក្នុងវិស័យកីឡា
- ពិនិត្យពាក្យស្នើសុំនិងផ្តល់ការលើកលែងប្រើប្រាស់ថ្នាំសម្រាប់ព្យាបាល
- ពិនិត្យតាមដានលទ្ធផលតេស្តនិងធ្វើការដោះស្រាយវិវាទដូប៉ា
- ពិនិត្យតាមដានការអនុវត្តអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា និងក្រមសកលលោកស្តីពីការប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡាជូនអង្គការយូណេស្កូនិងស្ថាប័នអន្តរជាតិពាក់ព័ន្ធ
- ពិនិត្យតាមដានការអនុវត្តវិធានប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ារបស់សហព័ន្ធកីឡាជាតិនិងស្ថាប័នកីឡាពាក់ព័ន្ធ
- ជំរុញក្រសួង ស្ថាប័នពាក់ព័ន្ធ វិស័យឯកជន ដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាលចូលរួមការប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា
- ពិនិត្យតាមដាននិងវាយតម្លៃលើការអនុវត្តការប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡានៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ចូលរួមកិច្ចប្រជុំកម្រិតជាតិ តំបន់ និងអន្តរជាតិពាក់ព័ន្ធនឹងការប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា
- ធ្វើរបាយការណ៍អំពីលទ្ធផលវឌ្ឍនភាពការប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡាជូននាយករដ្ឋមន្ត្រី
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីនាយករដ្ឋមន្ត្រី។

## ជំពូកទី៣
## ការប្រព្រឹត្តទៅរបស់ គ.ប.ដ.ក.

**មាត្រា៤ .-**

**គ.ប.ដ.ក.** ត្រូវប្រជុំយ៉ាងតិច២(ពីរ)ដងក្នុងមួយឆ្នាំ តាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីចាំបាច់ប្រធាន **គ.ប.ដ.ក.** អាចកោះប្រជុំវិសាមញ្ញ។

**គ.ប.ដ.ក.** មានសិទ្ធិប្រើរូបសញ្ញានិងត្រារបស់ក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ដំណើរការការងាររបស់ខ្លួន។

**គ.ប.ជ.ក.** មានលេខាធិការដ្ឋានមួយ ជាសេនាធិការសម្រាប់ដំណើរការការងារប្រចាំថ្ងៃរបស់ខ្លួន។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។

**មាត្រា៥ .-**

**គ.ប.ជ.ក.** មានអនុគណៈកម្មាធិការជំនាញចំនួន២(ពីរ)គឺអនុគណៈកម្មាធិការដោះស្រាយវិវាទដូប៉ា និងអនុគណៈកម្មាធិការលើកលែងការប្រើប្រាស់ថ្នាំព្យាបាល។

**គ.ប.ជ.ក.** មានសិទ្ធិស្នើសុំបង្កើតឬកែសម្រួលអនុគណៈកម្មាធិការជំនាញផ្សេងៗទៀតបានតាមការចាំបាច់និងស្របតាមនីតិវិធីជាធរមាន។

**មាត្រា៦ .-**

អនុគណៈកម្មាធិការដោះស្រាយវិវាទដូប៉ា មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - មេធាវី១រូប | ប្រធាន |
| - វេជ្ជបណ្ឌិត១រូប | អនុប្រធាន |
| - អតីតមន្ត្រីកីឡា១រូប | អនុប្រធាន |
| - អតីតអត្តពលិក១រូប | សមាជិក |
| - មេធាវី២រូប | សមាជិក |
| - វេជ្ជបណ្ឌិត២រូប | សមាជិក |
| - អ្នកជំនាញបច្ចេកទេសពាក់ព័ន្ធ២រូប | សមាជិក |

- សមាសភាពផ្សេងទៀតតាមការចាំបាច់។

សមាសភាពដែលចូលរួមក្នុងអនុគណៈកម្មាធិការនេះ ត្រូវមានលក្ខណសម្បត្តិកំណត់ដោយប្រធាន **គ.ប.ជ.ក.** ស្របតាមស្តង់ដាអន្តរជាតិស្តីពីការដោះស្រាយវិវាទដូប៉ានិងក្រមប្រឆាំងដូប៉ាពិភពលោក។

**មាត្រា៧ .-**

អនុគណៈកម្មាធិការដោះស្រាយវិវាទដូប៉ា មានតួនាទីនិងភារកិច្ចស្របតាមស្តង់ដាអន្តរជាតិស្តីពីការដោះស្រាយវិវាទដូប៉ានិងក្រមសកលលោកស្តីពីការប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាដូចខាងក្រោម៖

- ពិនិត្យតាមដានលទ្ធផលតេស្តរបស់មន្ទីរពិសោធន៍និងជូនដំណឹងដល់អត្តពលិកក្នុងករណីមានវិជ្ជមានសារធាតុដូប៉ាឬមានការរំលោភបំពានវិធានប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា
- ពិនិត្យសំណុំឯកសារពាក់ព័ន្ធក្នុងដំណាក់កាលនីតិវិធីប្រមូលសំណាកឬ/និងស្រាវជ្រាវលើការរំលោភបំពានវិធានប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា
- ពិនិត្យអំពីដំណើរការនៃការលើកលែងការប្រើប្រាស់ថ្នាំព្យាបាល
- ចេញលិខិតព្យួរអត្តពលិកជាបណ្តោះអាសន្នដោយមិនអនុញ្ញាតឱ្យចូលរួមប្រកួតកីឡានានាក្នុងករណីមានវិជ្ជមានសារធាតុដូប៉ាឬមានការរំលោភបំពានវិធានប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា
- រៀបចំសវនាការពាក់ព័ន្ធនឹងការរំលោភបំពានវិធានប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា
- ចេញសេចក្តីសម្រេចលើការរំលោភបំពានវិធានប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា
- ទទួលនិងពិនិត្យសំណុំឯកសារពាក្យបណ្តឹងរបស់អត្តពលិកដែលមិនសុខចិត្តនឹងសេចក្តីសម្រេចខាងលើ
- ពិនិត្យតាមដានការអនុវត្តក្រមសកលលោកស្តីពីការប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ានិងវិធានប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ារបស់អត្តពលិក

- ពិនិត្យតាមដានការដោះស្រាយវិវាទដូប៉ា ស្របតាមស្តង់ដាអន្តរជាតិស្តីពីការដោះស្រាយវិវាទដូប៉ា
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃសេចក្តីសម្រេចក្នុងការដោះស្រាយវិវាទដូប៉ាជូនអង្គការប្រឆាំងដូប៉ាក្នុងតំបន់និងទីភ្នាក់ងារពិភពលោកប្រឆាំងដូប៉ា តាមរយៈ **គ.ប.ដ.ក.**
- ធ្វើរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡាជូន **គ.ប.ដ.ក.** តាមរយៈលេខាធិការដ្ឋាននៃ **គ.ប.ដ.ក.** ។

**មាត្រា៨ .-**

អនុគណៈកម្មាធិការលើកលែងការប្រើប្រាស់ថ្នាំព្យាបាល មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - តំណាងក្រសួងសុខាភិបាល១រូប | ប្រធាន |
| - វេជ្ជបណ្ឌិតឯកទេស១រូប | អនុប្រធាន |
| - វេជ្ជបណ្ឌិត៥រូប | សមាជិក |
| - អ្នកជំនាញបច្ចេកទេសពាក់ព័ន្ធ៣រូប | សមាជិក |

- សមាសភាពផ្សេងទៀតតាមការចាំបាច់។

សមាសភាពដែលចូលរួមក្នុងអនុគណៈកម្មាធិការនេះ ត្រូវមានលក្ខណសម្បត្តិកំណត់ដោយប្រធាន **គ.ប.ដ.ក.** ស្របតាមស្តង់ដាអន្តរជាតិស្តីពីការលើកលែងការប្រើប្រាស់ថ្នាំព្យាបាល។

**មាត្រា៩ .-**

អនុគណៈកម្មាធិការលើកលែងការប្រើប្រាស់ថ្នាំព្យាបាល មានតួនាទីនិងភារកិច្ចស្របតាមស្តង់ដាអន្តរជាតិស្តីពីការលើកលែងការប្រើប្រាស់ថ្នាំព្យាបាលនិងក្រមសកលលោកស្តីពីការប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ា ដូចខាងក្រោម៖

- ទទួលនិងពិនិត្យពាក្យស្នើសុំលើកលែងការប្រើប្រាស់ថ្នាំព្យាបាលរបស់អត្តពលិក
- ពិនិត្យបញ្ជីសារធាតុនិងវិធីហាមឃាត់ក្នុងវិស័យកីឡា
- ពិនិត្យតាមដាននិងផ្តល់ការលើកលែងការប្រើប្រាស់ថ្នាំព្យាបាល
- ពិនិត្យនិងវាយតម្លៃប្រភេទជំងឺនិងថ្នាំដែលអត្តពលិកស្នើសុំប្រើប្រាស់សម្រាប់ព្យាបាល
- ធ្វើការសម្រេចលើការស្នើសុំប្រើប្រាស់ថ្នាំព្យាបាលរបស់អត្តពលិក
- បញ្ចូលសេចក្តីសម្រេចរបស់ខ្លួនទៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលប្រឆាំងដូប៉ា
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃសេចក្តីសម្រេចក្នុងការលើកលែងការប្រើប្រាស់ថ្នាំព្យាបាលជូនអង្គការតំបន់អាស៊ីអាគ្នេយ៍ប្រឆាំងដូប៉ា (SEARADO) និងទីភ្នាក់ងារពិភពលោកប្រឆាំងដូប៉ា (WADA) តាមរយៈ **គ.ប.ដ.ក.**
- ធ្វើរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡាជូន **គ.ប.ដ.ក.** តាមរយៈលេខាធិការដ្ឋាននៃ **គ.ប.ដ.ក.** ។

## ជំពូកទី៤
## ប្រភពធនធាននិងការគ្រប់គ្រងហិរញ្ញវត្ថុ

**មាត្រា១០ .-**

**គ.ប.ដ.ក.** មានធនធានសម្រាប់អនុវត្តសកម្មភាពការងារដោយថវិកាជាតិនៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**គ.ប.ជ.ក**. មានសិទ្ធិទទួលនិងគ្រប់គ្រងតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន នូវមូលនិធិដែលបានមកពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការអន្តរជាតិនិងពីប្រភពស្របច្បាប់ផ្សេងៗទៀត សម្រាប់បំពេញភារកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា១១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៩ រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៩៥ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការសម្រួលភារកិច្ចមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

### សម្រេច

**មាត្រា ១.-** សម្រួលភារកិច្ចលោក **ទេព ផល្លុន** ពីអគ្គាធិការរង នៃអគ្គាធិការដ្ឋាន មកជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ព្រហស្បតិ៍ ១១ រោច ខែ មិគសិរ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០២.១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...............សហវ.....

# ប្រកាស
## ស្តីពី
## ការតែងតាំងគ្លាក់ងារបើកផ្តល់ និងគ្លាក់ងារបើកផ្តល់ជំនួស នៅអគ្គាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤១២ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/ រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ. បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសារធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនី នៃប្លង់គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៣៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការអង្គភាពថវិកា របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ១៨៦ សហវ.ប្រក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ ស្តីពីការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូនប្រធានអង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១២៨២ សហវ.ប្រក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិកាកម្មវិធីរបស់អង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១១២៩ សហវ.ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨ ស្តីពីការកែសម្រួល និងការបង្កើតបន្ថែមគណនី និងអនុគណនីនៃចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកានៃប្រកាសលេខ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៦១៥ សហវ.ប្រកចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការបង្កើតបន្ថែមគណនី និងអនុគណនី នៃប្លង់គណនេយ្យសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## **សម្រេច**

**ប្រការ១.-**

ប្រាក់បៀវត្សរ៍មន្ត្រីរាជការ និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ នៃអគ្គាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបើកផ្តល់តាមរយៈភ្នាក់ងារបើកផ្តល់។

**ប្រការ២.-**

ត្រូវបានកែសម្រួល និងតែងតាំងភ្នាក់ងារបើកផ្តល់ និងភ្នាក់ងារបើកផ្តល់ជំនួស នៅអគ្គាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដូចមានសមាសភាពខាងក្រោម÷

| | | | |
|---|---|---|---|
| ១. លោក | **ឌឹា គេខ** | ប្រធានការិយាល័យ | ជាភ្នាក់ងារបើកផ្តល់ |
| ២. លោកស្រី | **ស្វាយ សុជានី** | មន្ត្រី | ជាភ្នាក់ងារបើកផ្តល់ជំនួស |
| ៣. លោក | **លឹម ច័ន្ទរដ្ឋារ៉ា** | មន្ត្រី | ជាភ្នាក់ងារបើកផ្តល់ជំនួស |

**ប្រការ៣.-**

លោក **ឌឹា គេខ** ជាភ្នាក់ងារបើកផ្តល់ លោកស្រី **ស្វាយ សុជានី** និងលោក **លឹម ច័ន្ទរដ្ឋារ៉ា** ជាភ្នាក់ងារបើកផ្តល់ជំនួសត្រូវ បានអនុញ្ញាតឱ្យបើកគណនីប្រាក់បញ្ញើនៅធនាគារ ដើម្បីទទួលមូលនិធិសម្រាប់យកទៅបើកប្រាក់បៀវត្សរ៍ និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ជូនមន្ត្រីរាជការ។

**ប្រការ៤.-**

បែបបទនៃការអនុវត្តបើកផ្តល់ប្រាក់បៀវត្សរ៍ និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ ត្រូវបានកំណត់ដោយសេចក្តីណែនាំក្រោយ។

**ប្រការ៥.-**

ភ្នាក់ងារបើកផ្តល់ ត្រូវទទួលខុសត្រូវផ្ទាល់ចំពោះប្រាក់កាស និងមូលនិធិដែលបានទទួល ដើម្បីយកទៅធ្វើការបើកផ្តល់ជូនមន្ត្រីរាជការ។

**ប្រការ៦.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៧.-**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកវិទ្យាស្ថាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- សាមីអង្គភាពថវិកា
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.........សហវ.........

# ប្រកាស
## ស្តីពី
## ការតែងតាំងវរជនិយុត្តិប្រធាន និងអនុប្រធាន នៅអគ្គាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤១២ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/ រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួល អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពី បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

- បានឃើញអនុក្រឹត្យលេខ ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងដាក់ឱ្យអនុវត្ត អង្គភាពថវិកា
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ៨៥៦ សហវ.ប្រក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការរៀបចំ និងចាប់ផ្តើមអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ ២៣៧ សហវ.ប្រក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ១៣៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការអង្គភាពថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៨៦ សហវ.ប្រក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ ស្តីពីការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិ ជូនប្រធានអង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១២៨២ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០១៦ ស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិកាកម្មវិធីរបស់អង្គភាពថវិកា
- បានឃើញប្រកាសលេខ ១១២៩ សហវ.ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨ ស្តីពីការកែសម្រួល និងការបង្កើតបន្ថែមគណនី និងអនុគណនីនៃចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកានៃប្រកាសលេខ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៦១៥ សហវ.ប្រកចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការបង្កើតបន្ថែមគណនី និងអនុគណនីនៃប្លង់គណនេយ្យសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ១.-**

ត្រូវបានកែសម្រួល និងតែងតាំងរដ្ឋទេយ្យករបុរេប្រទាន និងរដ្ឋទេយ្យករបុរេប្រទានរងរបស់អគ្គាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចខាងក្រោម÷

| | | |
|---|---|---|
| ១. លោក | **គៅ ទី** | ជារដ្ឋទេយ្យករបុរេប្រទាន |
| ២. លោកស្រី | **សំ ទត្តិយ៉ា** | ជារដ្ឋទេយ្យករបុរេប្រទានរង |
| ៣.លោក | **ម៉ម ហ៊ីណាង** | ជារដ្ឋទេយ្យករបុរេប្រទានរង។ |

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.-**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកវិទ្យាស្ថាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាមីអង្គភាពថវិកា
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ៧០៩ ........

ថ្ងៃ............ ខែ........ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី........ ខែ........ ឆ្នាំ២០២១

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ១១៦៧/១៥ គ.ស.ព ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការវិនិយោគបង្កើតរោងចក្រផលិតបំពង់ទីបដែកឧស្សាហកម្ម របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំប្រកាសបង្កើតរោងចក្រផលិតបំពង់ទីបដែកឧស្សាហកម្ម ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៥ របស់ក្រុមហ៊ុន ស្មៀល ហាប់ លីមីតធីត

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន **ស្មៀល ហាប់ លីមីតធីត (STEEL HUB LIMITED)** តំណាងដោយលោក **LEEKAN CHANAKORN VAROONCHAI** សញ្ជាតិថៃ កាន់លិខិតឆ្លងដែនលេខ AC2214454 ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ បង្កើតរោងចក្រ**ផលិតបំពង់ទីបដែកឧស្សាហកម្ម** ដែលមានទីតាំងស្ថិតនៅ**តំបន់សេដ្ឋកិច្ចពិសេសសានកូ ប៉ោយប៉ែត (ភូមិផ្សារកណ្តាល សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ)**។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code |
|---|---|
| បំពង់ទីបដែក | ២៤១០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំ ស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖" **រោងចក្រផលិតបំពង់ទីបដែក ស្មៀល ហាប់ លីមីតធីត** "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តបន្ទាយមានជ័យ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ**
**បច្ចេកវិទ្យា និងនវានុវត្តន៍**
**រដ្ឋលេខាធិការ**

**មាន សុភា**

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-រាជកិច្ច
-វិទ្យាស្ថានស្តង់ដារកម្ពុជា
-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
-សាលាខេត្តបន្ទាយមានជ័យ
-មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តបន្ទាយមានជ័យ
-រដ្ឋបាលក្រុងប៉ោយប៉ែត
-អង្គភាពរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសសានកូ ប៉ោយប៉ែត
-រដ្ឋបាលសង្កាត់ផ្សារកណ្តាល
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ៤២០........................

ថ្ងៃ...................... ខែ.............. ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី............ ខែ.......... ឆ្នាំ២០២១

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ០១៥/១៦ ស.ក.ត.ស.ព ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការវិនិយោគបង្កើតរោងចក្រផលិតគ្រឿងបង្គុំអេឡិចត្រូនិក របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១ របស់ក្រុមហ៊ុន ស៊ូមីត្រូនិច មេនញូហ្វេកជើរីង (ខេមបូឌា)

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន **ស៊ូមីត្រូនិច មេនញូហ្វេកជើរីង (ខេមបូឌា) (SUMITRONICS MANUFACTURING (CAMBODIA) CO., LTD.)** តំណាងដោយលោក **KAWASAKI IPPEI** សញ្ជាតិជប៉ុន កាន់លិខិតឆ្លងដែនលេខ TR7272282 ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៧ បង្កើតរោងចក្រផលិតគ្រឿងបង្គុំអេឡិកត្រូនិក ដែលមានទីតាំងស្ថិតនៅតំបន់សេដ្ឋកិច្ចពិសេស ប៉ោយប៉ែត ភីភី (ភូមិផ្សារកណ្តាល សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ)។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| គ្រឿងបង្គុំអេឡិកត្រូនិក | ២៦១០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖" រោងចក្រផលិតគ្រឿងបង្គុំអេឡិកត្រូនិក ស៊ូមីត្រូនិច មេនញូហ្វេកជើរីង (ខេមបូឌា)"

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

